ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

លេខៈ ១៧៦ ឧ.រ.ថ. សហវ.ប្រក. រាជធានីភ្នំពេញ,ថ្ងៃទី២៧ ខែ មីនា ឆ្នាំ២០០៩

លេខ : ១៩១ សហវ-ប្រក

# ប្រកាសអន្តរក្រសួង

## ស្តីពីការកំណត់ថ្លៃ

## ចុះបញ្ជី ពាក្យសុំ(កម្រៃអាជ្ញាប័ណ្ណ) ការពន្យារបន្ត ការផ្ទេរសិទ្ធិនៃអាជ្ញាប័ណ្ណធនធានរ៉ែ ឈ្នួលដីប្រចាំឆ្នាំនៃតំបន់សម្បទានសំរាប់ធ្វើការស្វែងរុករក និង/ឬធ្វើអាជីវកម្មធនធានរ៉ែ និង សួយសារធនធានរ៉ែ

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/០៥៥ ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ និងច្បាប់ទាំងឡាយដែលធ្វើវិសោធនកម្មច្បាប់នេះ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## សម្រេច

**ប្រការ ១.-**

រូបវន្តបុគ្គល នីតិបុគ្គលដែលដាក់ពាក្យសុំ ឬសម្បទានិកដែលមានអាជ្ញាប័ណ្ណធនធានរ៉ែ ត្រូវបង់ជូនរដ្ឋនូវថ្លៃតាមតារាងកំណត់ថ្លៃដូចខាងក្រោម៖

### ១. ថ្លៃចុះបញ្ជី

| | | |
|---|---|---|
| ១- អាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែ ................................ | ៤០.០០០ | (សែសិបពាន់) រៀល |
| ២- អាជ្ញាប័ណ្ណអណ្តូងរ៉ែបើកនិងការដ្ឋានវាយថ្ម សំរាប់ : | | |
| ២-១ ខ្សាច់សំណង់, ឡាតេរីត, ដីឥដ្ឋ.......................... | ៤០០.០០០ | (បួនរយពាន់) រៀល |
| ២-២ ថ្មសំណង់, ថ្មអារ, ក្រួស, ម្នាងសិលា និងថ្មផ្សេងទៀតដែលមានលក្ខណៈប្រហាក់ប្រហែល ........ | ៨០០.០០០ | (ប្រាំបីរយពាន់) រៀល |
| ៣- អាជ្ញាប័ណ្ណអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ ...................... | ២.០០០.០០០ | (ពីរលាន) រៀល |
| ៤-អាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ ........................................ | ៤០០.០០០ | (បួនរយពាន់) រៀល |
| ៥- អាជ្ញាប័ណ្ណស្វែងរុករក ............................................... | ៨០០.០០០ | (ប្រាំបីរយពាន់) រៀល |
| ៦-អាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ................ | ១.២០០.០០០ | (មួយលានពីររយពាន់) រៀល |

### ២. ថ្លៃពាក្យសុំ(តម្លៃអាជ្ញាប័ណ្ណ)

| | | |
|---|---|---|
| ១- អាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែ ................................ | ៥០.០០០ | (ហាសិបពាន់) រៀល |
| ២- អាជ្ញាប័ណ្ណអណ្តូងរ៉ែបើកនិងការដ្ឋានវាយថ្ម សំរាប់ : | | |
| ២-១ ខ្សាច់សំណង់, ឡាតេរីត, ដីឥដ្ឋ....................... | ៦០០.០០០ | (ប្រាំមួយរយពាន់) រៀល |
| ២-២ ថ្មសំណង់, ថ្មអារ, ក្រួស, ម្នាងសិលា និងថ្មផ្សេងទៀតដែលមានលក្ខណៈប្រហាក់ប្រហែល ....... | ១.៦០០.០០០ | (មួយលានប្រាំមួយរយពាន់) រៀល |
| ៣-អាជ្ញាប័ណ្ណអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ ...................... | ៨.០០០.០០០ | (ប្រាំបីលាន) រៀល |
| ៤- អាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ ដែលមាន : | | |
| ៤.១- កំលាំងពលកម្មតិចជាង៧នាក់.......................... | ៨០០.០០០ | (ប្រាំបីរយពាន់) រៀល |
| ៤.២- កំលាំងពលកម្មពី៧នាក់ ទៅ ១៤ នាក់................ | ១.៦០០.០០០ | (មួយលានប្រាំមួយរយពាន់) រៀល |
| ៤.៣- កំលាំងពលកម្មលើសពី ១៤ នាក់.......................... | ៣.២០០.០០០ | (បីលានពីររយពាន់) រៀល |
| ៥- អាជ្ញាប័ណ្ណស្វែងរុករក ............................................ | ៦.០០០.០០០ | (ប្រាំមួយលាន) រៀល |
| ៦- អាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ .............. | ១២.០០០.០០០ | (ដប់ពីរលាន) រៀល |

## ៣. ថ្លៃពន្យារបន្ត

| | | |
|---|---|---|
| ១- អាជ្ញាប័ណ្ណអណ្តូងរ៉ែបើកនិងការដ្ឋានវាយថ្ម សំរាប់ | | |
| ១-១ ខ្សាច់សំណង់, ឡាតេរីត, ដីឥដ្ឋ.................. | ៤២០.០០០ | (បួនរយម្ភៃពាន់) រៀល |
| ១-២ ថ្មសំណង់, ថ្មអារ, ក្រួស,ម្នាងសិលា និងថ្មផ្សេងទៀតដែលមានលក្ខណៈប្រហាក់ប្រហែល..... | ១.១២០.០០០ | (មួយលានមួយរយម្ភៃពាន់) រៀល |
| ២- អាជ្ញាប័ណ្ណអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ .............. | ៥.៦០០.០០០ | (ប្រាំមួយលានប្រាំមួយរយពាន់) រៀល |
| ៣- អាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ ដែលមាន : | | |
| ៣.១- កំលាំងពលកម្មតិចជាង៧នាក់................ | ៥៦០.០០០ | (ប្រាំរយហុកសិបពាន់) រៀល |
| ៣.២- កំលាំងពលកម្ម ពី៧ នាក់ ទៅ ១៤ នាក់..... | ១.១២០.០០០ | (មួយលានមួយរយម្ភៃពាន់) រៀល |
| ៣.៣- កំលាំងពលកម្មលើសពី ១៤ នាក់............ | ២.២៤០.០០០ | (ពីរលានពីររយសែសិបពាន់) រៀល |
| ៤- អាជ្ញាប័ណ្ណស្វែងរុករក..................................... | ៤.២០០.០០០ | (បួនលានពីររយពាន់) រៀល |
| ៥- អាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ......... | ៨.៤០០.០០០ | (ប្រាំបីលានបួនរយពាន់) រៀល |

## ៤. ថ្លៃផ្ទេរសិទ្ធិនៃអាជ្ញាប័ណ្ណធនធានរ៉ែ

| | | |
|---|---|---|
| ១-អាជ្ញាប័ណ្ណអណ្តូងរ៉ែបើកនិងការដ្ឋានវាយថ្មសំរាប់ : | | |
| ១-១ ខ្សាច់សំណង់, ឡាតេរីត, ដីឥដ្ឋ.................. | ២.០០០.០០០ | (ពីរលាន) រៀល |
| ១-២ ថ្មសំណង់, ថ្មអារ, ក្រួស, ម្នាងសិលា និងថ្មផ្សេងទៀតដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា .. | ៨.០០០.០០០ | (ប្រាំបីលាន) រៀល |
| ២-អាជ្ញាប័ណ្ណអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ ............. | ១៦.០០០.០០០ | (ដប់ប្រាំមួយលាន) រៀល |
| ៣-អាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ ដែលមាន : | | |
| ៣.១- កំលាំងពលកម្មតិចជាង៧នាក់ .............. | ២.០០០.០០០ | (ពីរលាន) រៀល |
| ៣.២- កំលាំងពលកម្មពី៧នាក់ ទៅ ១៤ នាក់..... | ៤.០០០.០០០ | (បួនលាន) រៀល |
| ៣.៣- កំលាំងពលកម្មលើសពី ១៤ នាក់.......... | ៦.០០០.០០០ | (ប្រាំមួយលាន) រៀល |
| ៤- អាជ្ញាប័ណ្ណស្វែងរុករក.................................. | ២០.០០០.០០០ | (ម្ភៃលាន) រៀល |
| ៥- អាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ...... | ២៤.០០០.០០០ | (ម្ភៃបួនលាន) រៀល |

## ៥. ថ្លៃឈ្នួលដីប្រចាំឆ្នាំនៃតំបន់សម្បទានសំរាប់ធ្វើការស្វែងរុករក និង/ឬធ្វើអាជីវកម្មធនធានរ៉ែ

| ប្រភេទអាជ្ញាប័ណ្ណធនធានរ៉ែ | ថ្លៃឈ្នួលដីប្រចាំឆ្នាំ |
|---|---|
| ១- អាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែ | |
| -ប្រភេទ **ក** (សំរាប់រ៉ែរបេះដាច់ ខ្សាច់ ក្រួស ឡាតេរីត) | ១០ (ដប់) ដុល្លារអាមេរិក/ហិកតា/ឆ្នាំ |
| -ប្រភេទ **ខ** (សំរាប់រ៉ែមាស) | ១៥ (ដប់ប្រាំ) ដុល្លារអាមេរិក/ហិកតា/ឆ្នាំ |
| -ប្រភេទ **គ** (សំរាប់រ៉ែត្បូងថ្មមានតម្លៃ-ពាក់កណ្តាលមានតម្លៃ) | ៣០ (សាមសិប) ដុល្លារអាមេរិក/ហិកតា/ឆ្នាំ |

| | |
|---|---|
| ២- អាជ្ញាប័ណ្ណអណ្ដូងរ៉ែបើកនិងការដ្ឋានវាយថ្ម | |
| -ប្រភេទ ក (សំរាប់ថ្មអារ និងថ្មបំបែក) | ៤០ (សែសិប) ដុល្លារអាមេរិក/ហិកតា/ឆ្នាំ |
| -ប្រភេទ ខ (សំរាប់រ៉ែរបេះដាច់ ខ្សាច់ ក្រួស ឡាតេរីត) | ២០ (ម្ភៃ) ដុល្លារអាមេរិក/ហិកតា/ឆ្នាំ |
| -ប្រភេទ គ (សំរាប់ថ្មកំបោរ) | ១០ (ដប់) ដុល្លារអាមេរិក/ហិកតា/ឆ្នាំ |
| ៣- អាជ្ញាប័ណ្ណអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ | |
| -ប្រភេទ ក (សំរាប់រ៉ែត្បូងថ្មមានតម្លៃ-ពាក់កណ្ដាលមានតម្លៃ) | ១២ (ដប់ពីរ) ដុល្លារអាមេរិក/ហិកតា/ឆ្នាំ |
| -ប្រភេទ ខ (សំរាប់ថ្មសំអាង) | ៤០ (សែសិប) ដុល្លារអាមេរិក/ហិកតា/ឆ្នាំ |
| ៤- អាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ | ថ្លៃឈ្នួលដីឬទីតាំងអនុវត្តតាមច្បាប់សារពើពន្ធ |
| ៥- អាជ្ញាប័ណ្ណស្វែងរុករក | |
| - ពីឆ្នាំទី១ ដល់ឆ្នាំទី២ | ០,១៥ (ដប់ប្រាំសេន)ដុល្លារអាមេរិក /ហិកតា/ឆ្នាំ |
| - ពីឆ្នាំទី៣ ដល់ឆ្នាំទី៤ | ០,៣០ (សាមសិបសេន) ដុល្លារអាមេរិក /ហិកតា/ឆ្នាំ |
| - ចាប់ពីឆ្នាំទី៥ឡើងទៅ | ០,៥០ (ហាសិបសេន)ដុល្លារអាមេរិក /ហិកតា/ឆ្នាំ |
| ៦- អាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ | |
| - ពីឆ្នាំទី១ ដល់ឆ្នាំទី៣ | ៤ (បួន) ដុល្លារអាមេរិក/ហិកតា/ឆ្នាំ |
| - ពីឆ្នាំទី៤ ដល់ឆ្នាំទី៥ | ៨ (ប្រាំបី) ដុល្លារអាមេរិក/ហិកតា/ឆ្នាំ |
| - ពីឆ្នាំទី៦ ឡើងទៅ | ១០ (ដប់) ដុល្លារអាមេរិក/ហិកតា/ឆ្នាំ |

## ៦. សួយសារលើតម្លៃធនធានរ៉ែ

| ក. ធនធានរ៉ែលោហៈ | អត្រាសួយសារ | |
|---|---|---|
| | សំរាប់ផ្គត់ផ្គង់ដល់រោងចក្រហើយដែលរោងចក្រនោះស្ថិតនៅក្រោមការគ្រប់គ្រងរបស់សម្បទានិកដែលមានអាជ្ញាប័ណ្ណធនធានរ៉ែ | សំរាប់គោលបំណងពាណិជ្ជកម្ម |
| - អង់ទីម៉ូនី (Sb) | ២.៥ % - ៣.៥% នៃតម្លៃលក់ផលិតផល ដោយផ្អែកតាមតម្លៃនៅលើទីផ្សារអន្តរជាតិ | ៤% - ៥% |
| - ក្រូម (Cr) | | |
| - ដែក (Fe) | | |
| - ម៉ង់កាណែស (Mn) | | |
| - ម៉ូលីបដែន (Mo) | | |
| - តង់ស្ទែន (W) | | |
| - មីណា/អាលុយមីញ៉ូម | | |
| - ទង់ដែង (Cu) | | |
| - ស័ង្កសី (Zn) | | |
| - សំណប៉ាហាំង (Sn) | | |

| | | |
|---|---|---|
| - សំណ (Pb) <br> - មាស (Au) <br> - ប្លាកទីនញ៉ូម (Pt) <br> - ប្រាក់ (Ag) <br> - អ៊ីមីនីត (Ti) និង <br> -ធនធានរ៉ែលោហៈផ្សេងទៀត ដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា | ២.៥ % - ៣.៥% នៃតម្លៃលក់ផលិតផល ដោយផ្អែកតាមតម្លៃនៅលើទីផ្សារអន្តរជាតិ | ៤% - ៥% |
| **ខ. ធនធានរ៉ែអលោហៈ (ធនធានរ៉ែឧស្សាហកម្ម)** | | |
| - ដីឥដ្ឋធ្វើស៊ីម៉ងត៍ | ០.១០ ដុល្លារអាមេរិក/តោនស៊ីម៉ងត៍ដែលផលិតបាន | ០.១០ ដុល្លារអាមេរិក/តោន |
| - កៅឡាំង | ១.២០ ដុល្លារអាមេរិក/តោននៃផលិតផលសំរេច | ១.២០ ដុល្លារអាមេរិក/តោន |
| - ថ្មកំបោរ | ០.២០ ដុល្លារអាមេរិក/តោនស៊ីម៉ងត៍ដែលផលិតបាន | ១.៥០ ដុល្លារអាមេរិក/តោន |
| - ថ្មហ្វូស្វ៊ីត | ១.២០ ដុល្លារអាមេរិក/តោនជីហ្វូសស្វាតដែលផលិតបាន | ១.២០ ដុល្លារអាមេរិក/តោន |
| - ខ្សាច់ស៊ីលីស | ១.៥០ ដុល្លារអាមេរិក/តោនខ្សាច់ឆៅ( មិនទាន់កែច្នៃ) | ១.៥០ ដុល្លារអាមេរិក/តោន |
| - អំបិល | ០.៥០ ដុល្លារអាមេរិក/តោនអំបិល | ០.៥០ ដុល្លារអាមេរិក/តោន |
| **គ. ត្បូងថ្មមានតម្លៃ ពាក់កណ្តាលមានតម្លៃ ថ្មសំអាង** | | |
| **គ.១. ត្បូងថ្មមានតម្លៃ** | | |
| - ពេជ្រ <br> - ត្បូងទទឹម <br> - ត្បូងកណ្តៀង <br> - មរកត និង <br> - រ៉ែត្បូងថ្មទាំងឡាយដែលមានគុណភាពប្រហាក់ប្រហែលគ្នា | ១៥ % នៃតំលៃលក់ផលិតផល នៅលើទីផ្សារអន្តរជាតិ | |
| **គ.២. ត្បូងថ្មពាក់កណ្តាលមានតម្លៃ** | | |
| -ត្បូងសេកុន(Zircon) <br> -អាមេទីស (Amethyst) <br> - តូប៉ាស <br> - រ៉ែត្បូងថ្មទាំងឡាយដែលមានគុណភាពប្រហាក់ប្រហែលគ្នា | ១៥ % នៃតំលៃលក់ផលិតផល នៅលើទីផ្សារអន្តរជាតិ | |
| **គ.៣. ថ្មសំអាង** | | |
| ហ្សេត, ថ្មម៉ាប, ប៉ាហ្គោឌីត, ក្រានីត កាល់សេដូន, អាស្វ៊ីត, អូប៉ាល់ធម្មតា, អាហ្គាត, ម៉ាឡាស៊ីក, ឈើថ្ម, ថ្មថ្លើមអណ្តើក និងថ្មទាំងឡាយដែលមានគុណភាពប្រហាក់ប្រហែល ។ | ១៥ % នៃតំលៃលក់ផលិតផល នៅលើទីផ្សារអន្តរជាតិ | |

| ឃ. ធនធានរ៉ែឥន្ធនៈរឹង | |
|---|---|
| - ធ្យូងថ្ម | ៧ % នៃតំលៃលក់ផលិតផល |
| - ធ្យូងភក់ | នៅលើទីផ្សារអន្តរជាតិ |

**ប្រការ ២.-**

អង្គភាពពាក់ព័ន្ធក្រោមចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ព្រមទាំងរូបវ័ន្តបុគ្គល នីតិបុគ្គល ឬសម្បទានិកដូចក្នុងប្រការ១ ដែលមានអាជ្ញាប័ណ្ណធនធានរ៉ែ ត្រូវទទួលបន្ទុកអនុវត្ត តាមប្រកាសនេះ ។

**ប្រការ ៣.-**

ប្រកាសនេះមានប្រសិទ្ធភាព និងចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**គាត ឈន់**

**រដ្ឋមន្ត្រី**
**ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល**

**ស៊ុយ សែម**

**ចម្លងជូន :**

- ខុទ្ទកាល័យព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន
- គ្រប់ខេត្ត-ក្រុង ( ដើម្បីជូនជ្រាប )
- ដូចប្រការ ២ ( ដើម្បីអនុវត្ត )
- ឯកសារ-កាលប្បវត្តិ